

# របាយការណ៍ប្រចាំឆ្នាំ ២០១៩

*លទ្ធផលសម្រេចបានសំខាន់ៗ*

ជីវិតធម្មជាតិនៅកម្ពុជា

NatureLife Cambodia

# មាតិកា


១. អង្គការជីវិតធម្មជាតិនៅកម្ពុជា៖ ចក្ខុវិស័យ និងបេសកកម្ម............................ ១

២. លទ្ធផលសម្រេចបានប្រចាំឆ្នាំ ២០១៩................................................... ៣

២.១ ទប់ស្កាត់ការផុតពូជ ៣

២.២ អភិរក្សទីជម្រក ៤

២.៣ អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍ ៥

២.៤ លើកកម្ពស់ជីវភាព និងបង្កើនការចូលរួមពីប្រជាមូលដ្ឋាន ៦

២.៥ កសាងសមត្ថភាព ៩

៣. របាយការណ៍ហិរញ្ញវត្ថុ ........................................................................ ១២

៤. ដៃគូ និងម្ចាស់ជំនួយ .......................................................................... ១៣




# ១. អង្គការជីវិតធម្មជាតិនៅកម្ពុជា៖ ចក្ខុវិស័យ និងបេសកកម្ម

អង្គការជីវិតធម្មជាតិនៅកម្ពុជា គឺជាអង្គការក្នុងស្រុកធ្វើការផ្នែកអភិរក្សដែលបានចុះបញ្ជីជាផ្លូវការក្នុងក្រសួងមហាផ្ទៃក្នុងខែកុម្ភៈ ឆ្នាំ២០១៧។ អង្គការជីវិតធម្មជាតិនៅកម្ពុជា គឺជាអង្គការដែលមិនស្វែងរកប្រាក់កម្រៃជាឯកជន អព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ និងមិនផ្តល់មធ្យោបាយជាសម្ភារ ហិរញ្ញវត្ថុ ឬធនធានមនុស្សដើម្បីគាំទ្រគណបក្សនយោបាយ ឬមនោគមវិជ្ជាណាមួយឡើយ។ អង្គការនេះត្រូវបានបង្កើតឡើងដោយមានការគាំទ្រយ៉ាងពេញទំហឹងពីអង្គការជីវិតសត្វស្លាបអន្តរជាតិ ( BirdLife International ) ក្រោមជំនួយផ្នែកហិរញ្ញវត្ថុពី មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីទទួលរងការគំរាមកំហែង (CEPF) តាមរយៈអង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN)។ អង្គការជីវិតធម្មជាតិនៅកម្ពុជា ត្រូវបានបង្កើតឡើងដោយស្ថាបនិក ១២នាក់ ដែលក្នុងនោះ១០នាក់ គឺជាបុគ្គលិកស្នូលរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិប្រចាំកម្ពុជា។ ការផ្តួចផ្តើមបង្កើតឡើងនេះ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រអន្តរកាលនៃការកសាងសមត្ថភាពអង្គការក្នុងស្រុករបស់អង្គការជីវិតសត្វស្លាបអន្តរជាតិដើម្បីអាចចាប់ជាដៃគូនាពេលអនាគត (គិតមកដល់បច្ចុប្បន្នអង្គការជីវិតសត្វស្លាបអន្តរជាតិមានដៃគូចំនួន ១២១ ក្នុងបណ្តាប្រទេសនានាជុំវិញពិភពលោក )។ បន្ទាប់ពីអង្គការជីវិតសត្វស្លាបអន្តរជាតិបង្កើតកម្មវិធីដោយផ្ទាល់នៅក្នុងវិស័យអភិរក្ស និងការកសាងសមត្ថភាពដល់អ្នកអភិរក្ស និងបុគ្គលិកក្នុងស្រុកអស់រយៈពេលជាង ១៥ឆ្នាំនៅក្នុងប្រទេសកម្ពុជា អង្គការជីវិតសត្វស្លាបអន្តរជាតិ កំពុងរៀបចំយុទ្ធសាស្ត្រធ្វើការជ្រើសរើសដៃគូក្នុងប្រទេសកម្ពុជា។ សមាជិកស្ថាបនិកទាំង ១២នាក់ របស់អង្គការជិវិតធម្មជាតិកម្ពុជា ជឿជាក់យ៉ាងថាបុគ្គលិកកម្ពុជានឹងអាចអនុវត្តបេសកកម្មរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិនេះបាន។



*កិច្ចប្រជុំក្រុមប្រឹក្សាភិបាលអង្គការជីវិតធម្មជាតិនៅកម្ពុជា លើកទីមួយ*

អង្គការជីវិតធម្មជាតិនៅកម្ពុជាមានចក្ខុវិស័យ បេសកកម្ម និងកម្មវិធីដូចខាងក្រោម៖

- **ចក្ខុវិស័យ** ៖ ទាំងអស់គ្នាដើម្បីរស់នៅប្រកបដោយសុខដុមរមនារវាងមនុស្ស និងធម្មជាតិ។
- **បេសកកម្ម** ៖ ធ្វើការអភិរក្សជីវចម្រុះតាមរយៈការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាពដើម្បីជាប្រយោជន៍របស់យើងទាំងអស់គ្នា។

និងបែងចែកជា**កម្មវិធីចំនួន៥៖**

១. ទប់ស្កាត់ការផុតពូជ
២. អភិរក្សទីជម្រក
៣. អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍
៤. លើកកម្ពស់ជីវភាព និងបង្កើនការចូលរួមពីប្រជាមូលដ្ឋាន
៥. កសាងសមត្ថភាព

ជីវិតធម្មជាតិនៅកម្ពុជា
NatureLife Cambodia

ទប់ស្កាត់ការផុតពូជ



អភិរក្សទីជម្រក



អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍



ការលើកកម្ពស់ជីវភាពប្រជាមូលដ្ឋាន



ការបង្កើនសមត្ថភាព



# ២. លទ្ធផលសម្រេចបានប្រចាំឆ្នាំ ២០១៩

## ២.១ ទប់ស្កាត់ការផុតពូជ

- ចូលរួមការពារ និងអភិរក្សសត្វត្មាតកម្ពុជា ដោយចូលជាសមាជិកក្រុមការងារអភិរក្សសត្វត្មាតកម្ពុជា និងចូលរួមកិច្ចប្រជុំរបស់ក្រុមការងារអភិរក្សសត្វត្មាតនៅកម្ពុជា ដើម្បីពិភាក្សា និងរៀបចំសកម្មភាពអភិរក្ស ទប់ស្កាត់កត្តាគំរាមកំហែងទៅលើសត្វត្មាត។
- រៀបចំទិវសត្វត្មាតអន្តរជាតិដើម្បីលើកកំពស់ការចូលរួមដល់សាធារណៈជនក្នុងកិច្ចការងារអភិរក្សសត្វត្មាតនៅកម្ពុជា




*កិច្ចប្រជុំរបស់ក្រុមការងារអភិរក្សសត្វត្មាតនៅកម្ពុជា*

## ២.២ អភិរក្សទីជម្រក

- ចូលរួមសហការជាមួយក្រសួងបរិស្ថាន និងអង្គការជីវិតសត្វស្លាបអន្តរជាតិកម្មវិធីប្រចាំកម្ពុជា ក្នុងការងាររៀបចំ និងដាក់បញ្ចូលតំបន់ការពារទេសភាពអន្លង់ព្រីងទៅជាតំបន់នៃបណ្តាញផ្លូវហោះហើរសត្វស្លាប នៅប្រទេសកម្ពុជាដោយជោគជ័យ។
- រៀបចំសកម្មភាពផ្សព្វផ្សាយ និងចាក់វីឌីអូរខ្លីស្តីអំពីសត្វក្រៀល ជីវសាស្ត្រសត្វក្រៀល និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើម នៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅ និងតំបន់ការពារ

ទេសភាពអន្លង់ព្រីង ដល់សិស្សានុសិស្ស និងធ្វើការរៀបចំការចុះកម្មសិក្សាដល់សិស្ស ទៅតំបន់ដីសើម និងមើលសត្វក្រៀល។

- បញ្ចូលនិងគាំទ្រដល់កម្មវិធីអប់រំអំពីសត្វក្រៀលនិងបរិស្ថានទៅក្នុងកម្មវិធីសិក្សារបស់កុមារថ្នាក់ទី៤ ទី៥ និងទី៦នៃសាលាបឋមសិក្សាក្តុលជ្រុំ សាលបឋមសិក្សាសង្គមមានជ័យ និងសាលាបឋមសិក្សាបន្ទាយធ្លាយនៃតំបន់ការពារទេសភាពបឹងព្រែកល្ពៅ។




*សកម្មភាពប្រគល់វិញ្ញាបនប័ត្រ អន្លង់ព្រីង ជាតំបន់នៃបណ្តាញផ្លូវហោះហើរសត្វស្លាប នៅប្រទេសកម្ពុជា*



*សកម្មភាពផ្សព្វផ្សាយ និងចាក់វីឌីអូរខ្លីស្តីអំពីសត្វក្រៀល ជីវសាស្ត្រសត្វក្រៀល និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី តំបន់ដីសើម នៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅ និងតំបន់ការពារទេសភាពអន្លង់ព្រីង*




*សំនួរ និងចម្លើយ ពីសត្វក្រៀល ជីវសាស្ត្រសត្វក្រៀល និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើម នៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅ និងតំបន់ការពារទេសភាពអន្លង់ព្រីង*

## ២.៣ អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍

- ការសិក្សាស្រាវជ្រាវពីសត្វស្លាបទេសន្តរប្រវេសន៍នៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅ ខេត្តតាកែវ។ យើងក៏បានធ្វើការកំណត់អំពីលក្ខណៈវិនិច្ឆ័យក្នុងការដាក់បញ្ចូលតំបន់នោះទៅជាតំបន់នៃបណ្តាញផ្លូវហោះហើរសត្វស្លាប នៅប្រទេសកម្ពុជា។
- ការសិក្សាស្រាវជ្រាវពីសត្វស្លាបទេសន្តរប្រវេសន៍ នៅក្នុងតំបន់ការពារទេសភាពអាងត្រពាំងថ្ម ខេត្តបន្ទាយមានជ័យ។ យើងបានធ្វើការកំណត់អំពីលក្ខណៈវិនិច្ឆ័យក្នុងការដាក់បញ្ចូលតំបន់នោះទៅជាតំបន់នៃបណ្តាញផ្លូវហោះហើរសត្វស្លាប នៅប្រទេសកម្ពុជា។
- ការចូលរួមរៀបចំទិវាសត្វស្លាបទេសន្តរប្រវេសន៍ឆ្នាំ ២០១៩ ក្រោមប្រធានបទ អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍ដោយកាត់បន្ថយការបំពុលដោយសំណល់ផ្លាស្ទិក ខេត្តកែប។ ទិវានេះមានការចូលរួមពីអភិបាលខេត្តកែប ក្រសួងបរិស្ថាន សិស្សានុសិស្ស និងអង្គការដៃគូ។
- ចូលរួមកិច្ចប្រជុំអំពីការងារអភិរក្សសត្វស្លាបទេសន្តរប្រវេសន៍ ក្នុងតំបន់អាស៊ាន ដែលរៀបចំដោយមជ្ឈមណ្ឌលអាស៊ានសម្រាប់ជីវៈចម្រុះ។



*សកម្មភាពក្នុងទិវាទិវាសត្វស្លាបទេសន្តរប្រវេសន៍ឆ្នាំ ២០១៩ ក្រោមប្រធានបទ អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍*



*សត្វក្រៀលក្នុងតំបន់ការពារទេសភាពបឹងព្រែកល្ពៅ ខេត្តតាកែវ*



*ការចុះសិក្សាពីសត្វស្លាបទេសន្តប្រវេសន៍ និងលក្ខណៈវិនិច្ឆ័យតំបន់ផ្លូវហោះហើរសត្វស្លាប*

## ២.៤ លើកកម្ពស់ជីវភាព និងបង្កើនការចូលរួមពីប្រជាមូលដ្ឋាន

- ចូលរួមរៀបចំកម្មវិធីទិវាតំបន់ដីសើមពិភពលោកឆ្នាំ ២០១៩ ក្រោមប្រធានបទ តំបន់ដីសើម និងការប្រែប្រួលអាកាសធាតុ ដែលចូលរួមក្នុងការលើកម្ពស់ការយល់ដឹង និងការអភិរក្សតំបន់ដីសើមពីសហគមន៍មូលដ្ឋាន។
- បញ្ជ្រាបការយល់ដឹងអំពីសត្វស្លាប និងជីវចម្រុះតាមបណ្តាញសង្គម ដោយធ្វើការបង្ហោះរូបភាព ឬចែករំលែកពត៌មានអំពីសត្វស្លាបដែលមានវត្តមាននៅប្រទេស នៅចំនេះដឹងដែលទាក់ទងនឹងសត្វស្លាប ដល់សាធារណៈជនក្នុងគោលបំណងបណ្តុះការស្រលាញ់សត្វស្លាប និងធម្មជាតិ ហើយចាប់ផ្តើមចូលរួមការអភិរក្ស។
- រៀបចំកម្មវិធីមហោស្រពសត្វស្លាប និងធម្មជាតិ ដោយសហការជាមួយក្រសួងបរិស្ថាន សកលវិទ្យាល័យភូមិន្ទភ្នំពេញ និងអង្គការដៃគូ។ កម្មវិធីមហោស្រពសត្វស្លាប និងធម្មជាតិ គឺប្រារព្ធឡើងនៅបរិវេណសកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយមានការចូលរួមពីអង្គការអភិរក្សសត្វស្លាប សាធារណៈជន សិស្សានុសិស្ស និងអ្នកដែលមកទេសនានៅវត្តភ្នំ សរុបប្រមាណជាង ៨០០០ នាក់។ កម្មវិធីនេះបានរៀបចំឡើងក្នុងរយៈពេល ១ ថ្ងៃ ដោយមានសកម្មភាពការមើលសត្វ ការសម្តែងសិល្បៈដែលផ្សារភ្ជាប់នឹងការអភិរក្សសត្វស្លាប និងធម្មជាតិ ការតាំងរូបភាពសត្វស្លាប ការគូរគំនូរសត្វស្លាប ការតាំងស្តង់ បទបង្ហាញទាក់ទងនឹងការងារអភិរក្សនៅក្នុងប្រទេសកម្ពុជា។




*សកម្មភាពសម្តែងក្នុងកម្មវិធីមហោស្រពសត្វស្លាប និងធម្មជាតិ*



*ស្តង់ពិពណ៌ និងការតាំងរូបថតសត្វស្លាបក្នុងកម្មវិធីមហោស្រពសត្វស្លាប និងធម្មជាតិ*

## ២.៥ កសាងសមត្ថភាព

- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់អង្គការជីវិតធម្មជាតិនៅកម្ពុជាប្រចាំឆមាស និងប្រចាំឆ្នាំ
- រៀបចំកិច្ចប្រជុំគណៈកម្មាការប្រតិបត្តិរបស់អង្គការជីវិតធម្មជាតិនៅកម្ពុជាប្រចាំខែ

- ចូលរួមពិព័រណ៍សត្វស្លាបអាស៊ី និងពិព័រណ៍សត្វស្លាបថៃ ក្នុងការសិក្សាបទពិសោធន៍ក្នុងការរៀបចំកម្មវិធី ចែករំលែកបទពិសោធន៍ និងបង្កើនទំនាក់ទំនងក្នុងបណ្ដាសមាគមន៍សត្វស្លាបជុំវិញពិភពលោក។
- កសាងសមត្ថភាពបុគ្គលិកដោយបញ្ជូនឱ្យទៅចូលរួមវគ្គបណ្ដុះបណ្ដាលមួយចំនួនដូចជា៖ វគ្គបណ្ដុះបណ្ដាលពីការគ្រប់គ្រង និងស្ដារតំបន់ដីសើម និងវគ្គបណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំក្នុងការងារអភិរក្សជីវៈចម្រុះ។



*កិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់អង្គការជីវិតធម្មជាតិនៅកម្ពុជាប្រចាំឆ្នាំ*




*ចូលរួមពិព័រណ៍សត្វស្លាបអាស៊ី ២០១៩*

# ៣. របាយការណ៍ហិរញ្ញវត្ថុ

**របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៩**

| | 2019<br>US$ |
|---|---|
| **ចំណូល** | |
| ចំណូលទទួលបានពីម្ចាស់ជំនួយ | 108,303.67 |
| វិភាគទានពីម្ចាស់ជំនួយឯកជន | 4,650.00 |
| ចំណូលផ្សេងៗ | 281.68 |
| | **113,235.35** |
| **ចំណាយ** | |
| ចំណាយលើបុគ្គលិក | 1,200.00 |
| សម្ភារៈការិយាល័យ/សម្ភារៈ/ឧបករណ៍ប្រើប្រាស់ | 73.85 |
| ទូរគមនាគមន៍ / ប៉ុស្ដិ៍ / អ៊ិនធឺណិត | 278.37 |
| ការងារអភិរក្ស និងសហគមន៍ | 6,500.72 |
| សិក្ខាសាលា / កិច្ចប្រជុំ | 29,953.44 |
| ឧបករណ៍និងសម្ភារៈផ្គត់ផ្គង់ | 2,090.70 |
| ការធ្វើដំណើរ | 2,068.58 |
| ចំណាយប្រយោល | 65.60 |
| | **42,231.26** |
| **ការទូទាត់ចំណូល និងចំណាយ** | **71,004.09** |
| **សមតុល្យពីឆ្នាំមុន** | **4,319.98** |
| **សមតុល្យបំណាច់ឆ្នាំ២០១៩** | **75,324.07** |

# ៤. ដៃគូ និងម្ចាស់ជំនួយ

## ស្ថាប័នរដ្ឋ

## អង្គការដៃគូ និងក្រុមការងារ

## ម្ចាស់ជំនួយ




**អង្គការជីវិតធម្មជាតិនៅកម្ពុជា**

រតនគិរី៖ ផ្ទះលេខ៣៥ ផ្លូវលេខ៣៣ ភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី

ភ្នំពេញ៖ ផ្ទះលេខ៣២A សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ

អ៊ីម៉ែល៖ admin@naturelifecambodia.org

គេហទំព័រ ៖ www.naturelifecambodia.org

លេខទំនាក់ទំនង៖ ០៧៨ ៧៣២ ២៤០ ឬ ០២៣ ៩៩៣ ៦៣១